

## ១. សេចក្តីផ្តើម

សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា "Cambodia Conservation Agriculture and Sustainable Intensification Consortium(CASIC)"គឺជាយន្តការថ្នាក់ជាតិមួយដែលត្រូវបានបង្កើតឡើងក្នុងការសហការនិងសម្របសម្រួល ជាមួយបណ្តាញនៃអង្គការជាច្រើន ដែលកំពុងអនុវត្តសកម្មភាពពាក់ព័ន្ធការងារអភិរក្សកសិកម្មនៅក្នុងប្រទេសកម្ពុជា ដូចជាទីផ្សារ ការស្រាវជ្រាវ គោលនយោបាយ និងការផ្តល់សេវាកម្ម ។ល។ ដើម្បីលើកកម្ពស់ការអនុវត្ត ការបង្កើតតម្រូវការសម្រាប់គ្រឿងម៉ាស៊ីនកសិកម្មនិងឧបករណ៍កសិកម្ម បង្កើនការដាំរុក្ខជាតិចម្រុះផ្សេងៗ ការទទួលបានគ្រាប់ពូជនៃដំណាំគម្របដីជាដើម ព្រមទាំងទទួលបានការចូលរួមពីវិស័យឯកជន ដើម្បីបំពេញនូវតម្រូវការទាំងនោះ។

## ២. គោលបំណង

សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ដើរតួជាវេទិកាដើម្បីលើកកម្ពស់ការអនុវត្តកសិកម្មអភិរក្ស តាមរយៈការគ្រប់គ្រងចំណេះដឹង (Knowledge Management) ការជះឥទ្ធិពលដល់អ្នកបង្កើតគោលនយោបាយ ការសម្របសម្រួលនិងបណ្តាញការងារការលើកកម្ពស់ និងការស្រាវជ្រាវ។ មុខងារទាំងនេះ នឹងគាំទ្រក្នុងការលើកកម្ពស់កសិកម្មអភិរក្ស ហើយនឹងនាំឱ្យមានតម្រូវការបង្កើតសេវាកម្មកសិកម្មអភិរក្ស។ កំណើននៃតម្រូវការនេះនឹងនាំឱ្យ មានការចាប់អារម្មណ៍ពីវិស័យឯកជន និងមានការចូលរួមរបស់តួអង្គទីផ្សារដទៃទៀត (Market actors´ engagement) ដូចជាការច្នៃប្រឌិតបន្ថែមទៀត ការទទួលយកក្នុងការអនុវត្តកសិកម្មអភិរក្សនិងគ្រឿងយន្តកសិកម្មពាក់ព័ន្ធការងារកសិកម្មអភិរក្ស។ ចំណាប់អារម្មណ៍និងការវិនិយោគពីវិស័យឯកជន នឹងនាំឱ្យផ្តល់សេវាកម្មកសិកម្មអភិរក្ស ដល់ប្រជាកសិករកាន់តែច្រើនក្នុងការអនុវត្តកសិកម្មអភិរក្ស។ ការអនុវត្តកសិកម្មអភិរក្ស នឹងធ្វើឱ្យប្រសើរឡើងនូវជីជាតិដី បង្កើនគុណភាពនិងបរិមាណនៃទិន្នផលដំណាំ ដែលជាហេតុនាំឱ្យមានការកើនឡើងប្រាក់ចំណូលសម្រាប់កសិករ និងការកាត់បន្ថយភាពក្រីក្រ។

## ៣. ទស្សនវិស័យ

ចក្ខុវិស័យនៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាគឺដើម្បីក្លាយជាវេទិកាដ៏ល្អមួយដែលបានបង្កើតឡើងសម្រាប់ធ្វើការជាមួយនឹងបណ្តាញនៃអង្គការនានា ដែលកំពុងធ្វើការលើបញ្ហាកសិកម្មអភិរក្សនៅក្នុងប្រទេសកម្ពុជា ដូចជា ទីផ្សា ការស្រាវជ្រាវ គោលនយោបាយ ការផ្តល់សេវាកម្ម។ ល់។ ដើម្បីសំរេចគោលដៅ វេទិកាមួយនេះ ជាបបមប្រមូលផ្តុំតួអង្គទីផ្សារទាំងអស់ដែលចូលរួមក្នុងការងារកសិកម្មអភិរក្សដើម្បីលើកកម្ពស់ការអនុវត្តកសិកម្មអភិរក្ស បង្កើតតំរូវការសំរាប់គ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្មដំណាំចម្រុះនិងលទ្ធភាពក្នុងការស្វែងរកនិងទទួលបានពូជដំណាំគម្របដី។ ល។ និងឱ្យមានការចូលរួមពីវិស័យឯកជន ដើម្បីបំពេញតំរូវការទាំងនោះ។

## ៤. បេសកកម្ម

បេសកកម្មរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គឺបង្កើតការគ្រប់គ្រងចំណេះដឹង ឬព័ត៌មានដែលទាក់ទងនឹងកសិកម្មអភិរក្ស ដើម្បីងាយស្រួលក្នុងការទទួលយកបានដោយកសិករខ្នាតតូចនិងកសិករខ្នាតមធ្យម (ពាក់កណ្តាលពាណិជ្ជកម្ម) ។ បង្កើតបរិយាកាសអំណោយផល ដើម្បីជំរុញការវិនិយោគ កសិកម្មអភិរក្សលើកកម្ពស់និងការធ្វើឱ្យប្រសើរឡើងដល់ការអនុវត្តកសិកម្មអភិរក្សនិងពង្រឹងកិច្ចសហការរវាងអ្នកពាក់ព័ន្ធក្នុងការងារកសិកម្មអភិរក្ស ។

## ៥. រចនាសម្ព័ន្ធដឹកនាំ




សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តភាពកម្ពុជា
បង្កើតឡើងដើម្បីសមាជិកទាំងអស់ ប៉ុន្តែមិនអនុវត្តនៅសកម្មភាពណាមួយ
ដែលជាតួនាទីរបស់សមាជិកខ្លួនឡើយ។

### ៥.១ គណៈកម្មការតម្រង់ទិសសម្ព័ន្ធកសិកម្មអភិរក្សនិង ប្រពលវប្បកម្មនិរន្តរភាពកម្ពុជា

គណៈកម្មការតម្រង់ទិសសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាត្រូវបានបង្កើតនិងទទួលស្គាល់ជាផ្លូវការតាមសេចក្តីសម្រេចស្តីពីការបង្កើតនិងតែងតាំងសមាសភាពគណៈកម្មការតម្រង់ទិសសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម៖

**ប្រធាន** (ថ្នាក់រដ្ឋលេខាធិការ)

១. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**អនុប្រធាន** (ថ្នាក់អនុរដ្ឋលេខាធិការ)

២. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សមាជិក**

៣. តំណាងក្រសួងមហាផ្ទៃ
៤. តំណាងក្រសួងបរិស្ថាន
៥. តំណាងក្រសួងធនធានទឹកនិងឧត្តុនិយម
៦. តំណាងក្រសួងកិច្ចការនារី
៧. តំណាងសភាពាណិជ្ជកម្មកម្ពុជា

គណៈកម្មការតម្រង់ទិសសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា មានភារកិច្ចដូចខាងក្រោម៖

១. ដឹកនាំ តំរង់ទិសដៅ ណែនាំ និងធ្វើការត្រួតពិនិត្យ លើដំណើរការកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅក្នុងវិស័យកសិកម្មនៅកម្ពុជា
២. ពិនិត្យនិងសម្រេចលើផែនការសកម្មភាពនិងថវិកា លើការអនុវត្តសកម្មភាពកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅក្នុងវិស័យកសិកម្ម
៣. ពិនិត្យ វាយតំលៃ និងសម្រេចលើរបាយការណ៍វឌ្ឍនភាពការងារកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅក្នុងវិស័យកសិកម្ម
៤. បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូន។

### ៥.២ គណៈកម្មការប្រតិបត្តិសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា

គណៈកម្មការប្រតិបត្តិសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាត្រូវបានបង្កើតនិងទទួលស្គាល់ជាផ្លូវការតាមសេចក្តីសម្រេចស្តីពីការបង្កើតនិងតែងតាំងសមាសភាពគណៈកម្មការតម្រង់ទិសសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពពាក់ព័ន្ធចំណុះឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងអង្គការដៃគូអភិវឌ្ឍន៍មួយចំនួន ដែលចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍និងលើកកម្ពស់ការអនុវត្តកសិកម្មអភិរក្សនៅកម្ពុជា។

គណៈកម្មការប្រតិបត្តិសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា មានភារកិច្ចដូចខាងក្រោម៖

១. រៀបចំផែនការសកម្មភាពនិងអនុវត្តផែនការសកម្មភាពកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅក្នុងវិស័យកសិកម្ម
២. ជាសេនាធិការឱ្យគណៈកម្មការតម្រង់ទិសសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា
៣. ពិគ្រោះយោបល់និងសម្របសម្រួលការងារទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅក្នុងវិស័យកសិកម្ម
៤. ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តសកម្មភាពកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅក្នុងវិស័យកសិកម្ម
៥. សិក្សា ស្រាវជ្រាវ និងធ្វើការផ្សព្វផ្សាយពាក់ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅក្នុងវិស័យកសិកម្ម និងបំផុសការគាំទ្រដល់ការងារកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅកម្ពុជា
៦. ទំនាក់ទំនងនិងសហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីកៀងគរថវិកាសម្រាប់អភិវឌ្ឍសកម្មភាព កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅកម្ពុជា
៧. បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូន។

គណៈកម្មការប្រតិបត្តិសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា មានលេខាធិការដ្ឋានមួយ ដែល ជួយគាំទ្រដល់ការងារសម្របសម្រួលនិងប្រតិបត្តិរបស់គណៈកម្មការនេះ ពាក់ព័ន្ធសកម្មភាពអនុគណៈកម្មការទាំង៥ដែលបាននឹងកំពុងប្រតិបត្តិដោយអង្គភាពរដ្ឋនិងសង្គមស៊ីវិលលើការងារកសិកម្មអភិរក្សនៅកម្ពុជា។ អនុគណៈកម្មការទាំង៤ រួមមាន៖

១. អនុគណៈកម្មការគ្រប់គ្រងចំណេះដឹងកសិកម្មអភិរក្ស (Sub-committee for Knowledge Management)
២. អនុគណៈកម្មការសម្របសម្រួលនិងបណ្ដាញកសិកម្មអភិរក្ស (Sub- committee for Coordination & Networking)
៣. អនុគណៈកម្មការលើកកម្ពស់កសិកម្មអភិរក្ស (Sub-committee for Promotion)
៤. អនុគណៈកម្មការស្រាវជ្រាវកសិកម្មអភិរក្ស (Sub-committee for Research)។

បន្ថែមពីនេះគណៈកម្មាធិការប្រតិបត្តិ CASIC ក៏មានអង្គភាពគាំទ្របច្ចេកទេស (TSU) ផងដែរ។ សមាជិកនៃ TSU គឺជាអ្នកជំនាញជាតិនិងអន្តរជាតិមកពីអង្គការក្នុងស្រុកនិងអន្តរជាតិដែលជាដៃគូអភិវឌ្ឍន៍របស់ CASIC ។ អ្នកជំនាញទាំងនេះស្ម័គ្រចិត្តជួយគាំទ្រឬផ្ដល់ការណែនាំលើបច្ចេកទេសក្នុងការអនុវត្តសកម្មភាពកសិកម្មអភិរក្ស។



ទីស្នាក់ការរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា
មានទីតាំងនៅទីស្នាក់ការកណ្ដាលរបស់អង្គការស្វីសខន់ថាក់
នៅអគារថានខប #៤៦ ជាន់ទី៧ មហាវិថីម៉ៅសេទុង (២៤៥)
សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងទៅកាន់លេខាធិការរបស់
សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា
តាមរយៈលេខទូរស័ព្ទ 015 898 448

# សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា





## 1. Introduction

Cambodia Conservation Agriculture and Sustainable Intensification Consortium (CASIC) is a national mechanism established to collaborate and coordinate with a network of organizations that are implementing activities related to Conservation Agriculture (CA) in Cambodia such as marketing, research, policy and service delivery etc. by promoting CA practices, creating demand for CA machinery and implements, increase the diversification of crops, the accessibility of cover crops, and the participation of the private sector to meet the needs.

## 2. Purpose

CAISC acts as a platform to promote CA practices through knowledge management, influencing to policy makers, coordination and networking and promotions. These functions will support in promoting CA and will lead to demand creation of CA services. This increment of demand will lead to increase interest from the private sectors and other market actors' engagement, such as more innovation and uptake of CA practices and related machinery. The interest and investment from the private sectors will lead to provide CA services to more and more farmers implementing CA practices. The use of CA practices will result in improvement in soil fertility, accelerate in quality and quantity of their yields, consequently leading to income increase for the farmers and ultimately poverty alleviation.

## 3. Vision

The vision of CASIC is to be a well-established platform with a vast network of organizations that are working on the CA issues in Cambodia, e.g. markets, research, policies, service provision etc. To achieve this, a platform that can initially bring together all the market actors involved in CA to promote CA practices, create demand for the required CA machinery and implements, plant diversity and availability/access to seed of cover crops etc. and get private sector engagement to fulfil those needs.

## 4. Mission

CASIC is to establish knowledge management of CA related resources for easy access by smallholder farmers and semi-commercial farmers; create an enabling environment to boost investment in CA; promote and enhance CA practices and enhance collaboration between stakeholders in CA.

## 5. Organizational Structure




*CASIC is formed to support its members and will not carry out any activities as a function of the members.*

### 5.1 CASIC Steering Committee

The CASIC Steering Committee was established and formally recognized by the Decision on the establishment and appointment of the composition of the CASIC Steering Committee by the Ministry of Agriculture Forestry and Fisheries (MAFF) following:

**Chair**

1. Representative from MAFF (Secretary of State Level)

**Vice Chair**

2. Representative from MAFF (Under Secretary of State Level)

**Member**

3. Representative from Ministry of Interior
4. Representative from Ministry of Education
5. Representative from Ministry of Water Resources Management
6. Representative from Ministry of Women Affairs
7. Representative from Cambodia Chamber of Commerce

The CASIC Steering Committee has its roles and responsibilities as below:

1. To manage, guide, supervise, and monitor the performance of CA and sustainable intensification in Cambodia agricultural sector;
2. To review and approve action plan and budget on implementation of CA and sustainable intensification in agricultural sector;
3. To review, evaluate and approve progress report of CA and sustainable intensification in agricultural sector;
4. To perform other tasks assigned by MAFF

## 5.2 CASIC Executive Board Committee

The CASIC Executive Board Committee was established and formally recognized by the Decision on the establishment and appointment of the composition of the CASIC Executive Board Committee by MAFF. This committee consists of relevant organizations under MAFF and development partners involved in developing and promoting CA practices in Cambodia.

The CASIC Executive Board Committee has the following roles and responsibilities:

1. To prepare action plan and implement on CA and sustainable intensification in agricultural sector;
2. To serve as secretariat for CASIC Steering Committee;
3. To consult and coordinate activities related to CA and sustainable intensification in agricultural sector;
4. To review, monitor and evaluate on implementation of action plan for CA and sustainable intensification in agricultural sector;
5. To study, research and disseminate information related to CA and sustainable intensification in agricultural sector;
6. To communicate and collaborate with relevant development partners on fund raising for the development of CASIC;
7. To perform other tasks assigned by MAFF.

The CASIC Executive Board Committee has a secretariat that provides supports on coordination of CASIC Executive Board Committee with five sub-committees that are implementing by public and civil society as below:

1. Sub-Committee for Knowledge Management;
2. Sub-Committee for Advocacy;
3. Sub-Committee for Coordination & Networking;
4. Sub-Committee for Promotion

In addition, CASIC Executive Committee also has Technical Support Unit (TSU). Members of TSU are national and international experts from local and international organizations who are development partners of CASIC. These experts volunteer to assist, support or provide guidance on CA techniques.



The Head Office of CASIC is located at the head-quarter of Swisscontact Cambodia at Tower # 46, 7th Mao Tse Toung Blvd (245), Boeng Trabek, Khan Chamkarmon, Phnom

For more information, please contact Secretariat of CASIC: 015 898 448

# Cambodia Conservation Agriculture and Sustainable Intensification Consortium (CASIC)

